អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គភាពគាំពារជនរងគ្រោះ
Victims Support Section
Section d'appui aux victimes

ភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១

# សេចក្តីរំលឹកព័ត៌មាន

## វេទិកាថ្នាក់តំបន់លើកទី៦សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០២

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកាថ្នាក់តំបន់លើកទី៦នៅខេត្តកំពត សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលទើបទទួលស្គាល់ថ្មីៗនេះ នៃសំណុំរឿង០០២ ចំនួន ៤៥០ នាក់ មកពីខេត្តកំពត កែប កំពង់សោម កំពង់ស្ពឺ និងកោះកុង។ វេទិកាថ្នាក់តំបន់លើកនេះនឹងប្រព្រឹត្តទៅនៅ ***សណ្ឋាគារតាឌីII ក្រុងកំពត នៅថ្ងៃព្រហស្បតិ៍ ទី២៨ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង៧:៣០ ព្រឹក*** *(អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីនឹង ត្រូវបានរក្សាជាសម្ងាត់)* ។

ដើមបណ្តឹងរដ្ឋប្បវេណីទាំង ៤៥០នាក់ ដែលនឹងចូលរួមវេទិកាថ្នាក់តំបន់លើកនេះ ស្ថិតក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២ ដែលត្រូវបានអង្គបុរេជំនុំជម្រះ ទទួលស្គាល់ចំនួន ១.៧២៨ នាក់ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១នេះ។ រហូតមកទល់ពេលនេះ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ សរុបទាំងអស់មានចំនួន ៣.៨៥០ នាក់។

វេទិកាថ្នាក់តំបន់នេះគឺជាសកម្មភាពដ៏សំខាន់មួយក្នុងចំណោមសកម្មភាពនានារបស់អង្គភាពគាំពារជនរងគ្រោះក្នុងការលើកកម្ពស់ការចូលរួមរបស់ជនរងគ្រោះឲ្យកាន់តែទូលំទូលាយក្នុងដំណើរការរបស់ អ.វ.ត.ក ក្នុងឆ្នាំ ២០១១ និងដើម្បីពង្រឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការច្បាប់សម្រាប់សំណុំរឿង០០២។ វេទិកាថ្នាក់តំបន់ នេះមានគោលបំណងផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណី ៖

- ជួបជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីពិភាក្សាអំពីសិទ្ធិក្នុងការដាក់ពាក្យបណ្តឹង នីតិវិធីចូលរួមនៅក្នុងដំណើរការកាត់ក្តី ក៏ដូចជាប្រមូលគំនិតដែលពាក់ព័ន្ធនឹងសំណងដែលស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរៀបចំគម្រោងសំណងនិងស្នើទៅកាន់ អ.វ.ត.ក ។
- ជួបជាមួយមន្ត្រីមកពីការិយាល័យនានានៃ អ.វ.ត.ក និងតំណាងសង្គមស៊ីវិល ដើម្បីស្វែងយល់ពីការវិវឌ្ឍថ្មីៗរបស់តុលាការ។
- ដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០១ ដើម្បីចែករំលែកបទពិសោធន៍សម្រាប់សំណុំរឿង០០២។

ចាប់ពីឆ្នាំ២០០៩ ដល់ខែកក្កដាឆ្នាំ២០១១នេះ អង្គភាពគាំពារជនរងគ្រោះបានរៀបចំដោយជោគជ័យនូវវេទិកាថ្នាក់តំបន់ចំនួន ៩ លើករួចមកហើយ ដោយមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណីនិងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២,៩៦៥នាក់ មកពី២៤ខេត្ត រាជធានី នៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

**អ៊ឹម សុភា**

ប្រធានកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ

ទូរស័ព្ទចល័ត: ០៧៧ ៧៧៧ ៣៦៧

អ៊ីម៉ែល: im.sophea@eccc.gov.kh